# សិទ្ធិបោះឆ្នោត



## ក. សេចក្ដីផ្ដើម :

ដោយសារតែមនុស្សគ្រប់រូបរស់នៅជាមួយគ្នាជាក្រុម ពួកគេ**ចាំបាច់ត្រូវចូលរួម**នៅក្នុងសេចក្ដីសំរេចណាមួយ ដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ ។

ក្នុងនាមជាប្រជាពលរដ្ឋ ពួកគេអាចចូលរួម**ក្នុងការងារសាធារណៈ** :

- **ដោយផ្ទាល់:** ដោយការប្រើប្រាស់អំណាចជាសមាជិកនៃអង្គនីតិបញ្ញត្តិ (សភាជាតិ និងព្រឹទ្ធសភា) ឬដោយកាន់កាប់ការិយាល័យប្រតិបត្តិណាមួយ ។
- **ដោយមិនផ្ទាល់:** តាមរយៈការជ្រើសរើសដោយសេរីនូវតំណាងនៅក្នុងអង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ ។

តំរូវការចូលរួមជាចាំបាច់ ត្រូវបានការពារដោយ**សិទ្ធិបោះឆ្នោត** :

| មាត្រា៣៤ CC: | មាត្រា២៥ ICCPR: |
|---|---|
| ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ <u>មានសិទ្ធិបោះឆ្នោត និង មានសិទ្ធិឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោត</u> ។ | ដោយពុំគិតទៅលើលក្ខខណ្ឌផ្សេងៗចែងក្នុងមាត្រា២ និងការកំណត់ព្រំដែនមិនសមហេតុផល ប្រជារាស្ត្រគ្រប់រូបមានសិទ្ធិ និងមានលទ្ធភាពក្នុងការ:<br>ក. ចូលរួមក្នុងការងារសាធារណៈ ដោយផ្ទាល់ ឬតាមរយៈតំណាង ដែលខ្លួនជ្រើសរើសដោយសេរី<br>ខ. <u>បោះឆ្នោត ឬឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោត</u> នៅក្នុងដំណើរការបោះឆ្នោតមួយទៀងទាត់ ត្រឹមត្រូវ ជាសកល ស្មើភាព និងជាសំងាត់ ធានានូវការបញ្ចេញឆន្ទៈដោយសេរីរបស់អ្នកបោះឆ្នោត ។ |

**បង្ហាញឆន្ទៈរបស់ប្រជាជន**[៤២]
**និង**
**ប្រតិភូអំណាចរបស់ពួកគេក្នុងការសំរេចលើជោគវាសនារបស់ពួកគេឱ្យទៅតំណាងរាស្ត្រដែលគេបានបោះឆ្នោត**

> មាត្រា៥១ CC:
> ព្រះរាជាណាចក្រកម្ពុជាអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។
>
> ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។
>
> អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងប្រព័ន្ធតុលាការ ។

## ខ. គោលការណ៍ជាមូលដ្ឋាននៃការបោះឆ្នោតបែបប្រជាធិបតេយ្យ :

អ្នកតំណាងរាស្ត្រដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោត **ត្រូវទទួលខុសត្រូវ**ចំពោះមុខប្រជារាស្ត្រ និងជាតំណាងរាស្ត្រក្នុងរយៈពេលមួយមានកំណត់ ។ បន្ទាប់ពីនោះមក ពួកគេត្រូវប្រឈមមុខនឹងការបោះឆ្នោតជាថ្មី និងត្រូវប្រណាំងប្រជែងដើម្បីសន្លឹកឆ្នោតម្តងទៀត ។ នេះជាការធានា ថា**អំណាចនីតិប្រតិបត្តិស្ថិតនៅលើឆន្ទៈរបស់ប្រជាពលរដ្ឋ** និងអាចចាត់ទុកជាការទទួលខុសត្រូវមួយនៅអណត្តិក្រោយ (ឧទាហរណ៍: បើសិនមិនត្រូវបានជ្រើសរើសម្តងទៀត) ។

ការបោះឆ្នោតមានន័យថាជាការជ្រើសរើសនូវដំណោះស្រាយខុសៗគ្នាចំពោះបញ្ហាសាធារណៈ ដូចដែលត្រូវបានលើកឡើងដោយគណបក្សនយោបាយ ឬបេក្ខជន ។ និន្នាការនៃការជ្រើសរើស និងការទទួលខុសត្រូវរបស់តំណាងរាស្ត្របង្ហាញឱ្យឃើញថា អ្នកបោះឆ្នោតត្រូវបានទទួល**ពត៌មាននានា** និង**អាចពិភាក្សាដោយសេរី**អំពីគណបក្សនយោបាយ បេក្ខជន គោលដៅរបស់គណបក្ស សកម្មភាពរបស់រដ្ឋាភិបាល និងការបំពេញការងាររបស់សមាជិកសភា ។

**ហេតុដូច្នេះហើយ សេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងការបង្កើតសមាគម ជាលក្ខខណ្ឌចាំបាច់សំរាប់ការប្រើប្រាស់សិទ្ធិបោះឆ្នោតឱ្យមានប្រសិទ្ធិភាព និងត្រូវបានការពារទាំស្រុង ។**

លើសពីនេះទៅទៀត **ការបញ្ចេញឆន្ទៈនយោបាយដោយសេរីរបស់អ្នកបោះឆ្នោត** ត្រូវការការពារប្រឆាំងនឹងឥទ្ធិពលមិនត្រឹមត្រូវណាមួយ ។

ដើម្បីធានាឱ្យការបោះឆ្នោតអាចសំរេចបាននូវគោលដៅ និងតួនាទីដូចបានបញ្ជាក់ខាងលើដោយប្រសិទ្ធិភាព គេបានកំណត់នូវគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធបោះឆ្នោតបែបប្រជាធិបតេយ្យនៅក្នុងច្បាប់ជាច្រើន។ គោលការណ៍ទាំងនេះអនុវត្តចំពោះការបោះឆ្នោតគ្រប់ប្រភេទទាំងអស់ ។

ការបោះឆ្នោតមួយត្រូវតែមានលក្ខណៈ :

[៤២] ពាក្យថា "លទ្ធិប្រជាធិបតេយ្យ" មានន័យថា: ការគ្រប់គ្រងដោយប្រជាជន!

- ជាសកល (ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិបោះឆ្នោតនៅក្នុងវ័យមួយ)
- ស្មើភាព (មនុស្សម្នាក់ៗមានតែមួយសំលេងប៉ុណ្ណោះ គ្មានការបែងចែករវាងអ្នកបោះឆ្នោតទេ)
- ដោយផ្ទាល់ (បេក្ខជនត្រូវបានជ្រើសរើសដោយផ្ទាល់ មិនអាចតាមរយៈអ្នកណាម្នាក់បានទេ)
- សំងាត់ (ការដាក់សន្លឹកឆ្នោតទៅក្នុងប្រអប់ឆ្នោតធានាជាលក្ខណៈឯកជន)
- សេរី (គ្មានការគំរាមកំហែង ឬ ឥទ្ធិពលមិនសមស្របណាមួយចំពោះអ្នកបោះឆ្នោតនៅក្នុងដំណើរការបោះឆ្នោតទាំងមូល)

មាត្រា៧៦ នៃ CC:

រដ្ឋសភាមានសមាជិកយ៉ាងតិច១២០រូប ។ តំណាងរាស្ត្រត្រូវជ្រើសតាំងដោយការបោះឆ្នោតដោយសេរី ជាសកល ដោយស្មើភាព ដោយចំពោះ និងតាមវិធី ជ្រើសរើសឆ្នោតជាសំងាត់ ។

មាត្រា២៥ នៃ ICCPR:

ប្រជាពលរដ្ឋម្នាក់ៗត្រូវមានសិទ្ធិ ... បោះឆ្នោត ឬឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោត នៅក្នុងដំណើរការបោះឆ្នោតមួយ ទៀងទាត់ត្រឹមត្រូវ ជាសកល ស្មើភាព និងជាសំងាត់ ធានានូវការបញ្ចេញឆន្ទៈដោយសេរីរបស់អ្នកបោះឆ្នោត ។

គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានផ្តល់នូវការពិពណ៌នាយ៉ាងពិស្តារមួយលើគោលការណ៍ នៃការបោះឆ្នោតដោយប្រជាធិបតេយ្យ ដូចមានចែងក្នុងមាត្រា២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងសិទ្ធិនយោបាយ[៤៣] ។ នៅក្នុងគេហទំព័រ "បណ្តាញសិទ្ធិមនុស្សអន្តរជាតិ"[៤៤] យើងអាចរកឃើញនូវ ពត៌មានពិស្តារ និងសេចក្តីសំរេច (យុត្តិសាស្ត្រ) ផ្សេងៗទៀតអំពីការបោះឆ្នោត និងការបោះឆ្នោតជាអន្តរជាតិ ។

## គ. ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ :

ជាទូទៅ គោលការណ៍៤ជាបឋម ("ជាសកល" "ដោយស្មើភាព" "ដោយចំពោះ" និង"ដោយសំងាត់") មិនបណ្តាលឱ្យមានបញ្ហាទេនៅក្នុងប្រទេសកម្ពុជា ។

១. ប៉ុន្តែគោលការណ៍នៃការបោះឆ្នោតដោយ"**សេរី**"មួយ បង្កនូវបញ្ហាមួយចំនួននៅក្នុងការអនុវត្តន៍ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ។ ជារឿយៗ ការបញ្ចេញនូវឆន្ទៈដោយសេរីរបស់អ្នកបោះឆ្នោតត្រូវបានប៉ះពាល់ដោយការទិញសន្លឹកឆ្នោត និងការគំរាមកំហែង ។

ស៊ីជំរៅជាងនេះទៅទៀត គោលការណ៍នៃការបោះឆ្នោតដោយសេរីទាមទារឱ្យ:

- **ផ្តល់នូវនីតិវិធីដ៏មានប្រសិទ្ធិភាពដល់អ្នកបោះឆ្នោត ដើម្បីប្តឹង**អំពីការរំលោភបំពានលើការបញ្ចេញនូវឆន្ទៈនយោបាយដោយសេរីរបស់ពួកគេ
- មាន**ការស៊ើបអង្កេតដោយហ្មត់ចត់** និងជាបន្ទាន់លើបណ្តឹងទាំងអស់នោះ
- មាន**ការដាក់ទណ្ឌកម្មដោយច្បាប់រដ្ឋបាល និងច្បាប់ព្រហ្មទណ្ឌ** ចំពោះការគំរាមកំហែង ឬឥទ្ធិពលមិនសមស្របផ្សេងៗទៀតលើអ្នកបោះឆ្នោត ។

[៤៣] មើលមាត្រា២៥ ICCPR តាមរយៈ www.unhchr.ch/html/menu3/b/a_ccpr.htm និងចុចលើការពិពណ៌នាលើមាត្រានេះ
[៤៤] មើល www.hrni.org និងចុចលើ : សិទ្ធិនិងសេរីភាព/សិទ្ធិសំភារ:/សិទ្ធិចូលរួមជាមួយរដ្ឋាភិបាល

២. ដំណើរការនៃការបោះឆ្នោតដោយ "**យុត្តិធម៌**" ភាគច្រើន មិនត្រូវបានធានាទេនៅក្នុងការអនុវត្តន៍ជាក់ស្តែង ។ ទោះបីជាគ្មានបទបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ឬច្បាប់បោះឆ្នោតកម្ពុជា ឬកតិកាសញ្ញាអន្តរជាតិ ទាមទារឱ្យជាក់លាក់ថាការបោះឆ្នោតត្រូវតែយុត្តិធម៌ក៏ដោយ ក៏ប៉ុន្តែគោលការណ៍នេះមាន និងអាចអនុវត្តបាន ។ គំនិតនេះស្តែងចេញមកពីមាត្រា៥១ CC ដែលចែងថា ព្រះរាជាណាចក្រកម្ពុជាអនុវត្តតាមរបបប្រជាធិបតេយ្យសេរី និងប្រកាន់ខ្ជាប់នូវគោលការណ៍ពហុបក្សដែលមានន័យថាគណបក្សនយោបាយ ឬបេក្ខជនខុសៗគ្នាទាំងអស់ត្រូវមាន"ឱកាស"ដូចគ្នា (=យុត្តិធម៌) ដើម្បីចូលរួមនៅក្នុងកិច្ចការរដ្ឋ ។ (មើលបុព្វកថា មាត្រា១ I មាត្រា៣៤ I មាត្រា៣៥ I II និងមាត្រា៥០ I CC) ។

**គោលការណ៍នៃពហុបក្សធានាថា បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវមានឱកាសស្មើគ្នាដើម្បីចូលរួមក្នុងការបោះឆ្នោត ។**

ក្នុងករណីដូចគ្នានេះដែរ **សិទ្ធិបោះឆ្នោត** (មាត្រា៣៤ CC) រាប់បញ្ចូលដោយតុល្យភាពផងដែរ ដែលថាអ្នក**បោះឆ្នោតត្រូវតែមានឱកាសស្មើគ្នាដើម្បីចូលរួមក្នុងដំណើរការបោះឆ្នោត** ។ ជាពិសេសមានន័យថា គាត់ត្រូវបានផ្តល់ឱ្យនូវឱកាសគ្រប់គ្រាន់ដើម្បីចុះឈ្មោះបោះឆ្នោត និងដើម្បីបោះឆ្នោត ។

ជាលក្ខណៈពិស្តារជាងនេះទៅទៀត គោលការណ៍នៃការបោះឆ្នោតដោយ"**យុត្តិធម៌**"ទាមទារឱ្យមានៈ

- **ការទទួលបាននូវការផ្សព្វផ្សាយពត៌មានស្មើៗគ្នាចំពោះភាគីទាំងអស់** (ជាពិសេសគណបក្សតូចៗ និងគណៈបក្សប្រឆាំង)

  ឧទាហរណ៍: សំរាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០២ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបង្កើតនូវវិធាននានាសំរាប់គ្រប់គ្រងការផ្សព្វផ្សាយ ដើម្បីធានាដល់ការទទួលបានពត៌មានស្មើគ្នា ។

- **ការអប់រំដល់អ្នកបោះឆ្នោតឱ្យបានគ្រប់គ្រាន់**[៤៥]
- **ច្បាប់ស្តីពីគណបក្សនយោបាយ**ដែលមិនរិតត្បិត ប៉ុន្តែគាំទ្រដល់ការបង្កើត និងដំណើរការគណៈបក្ស-នយោបាយ

  ឧទាហរណ៍: ការទាមទារថ្លៃឈ្នួលផ្ញើសផ្ទាសលើការចុះឈ្មោះ (មើលមាត្រា២០ XI នៃច្បាប់ស្តីពីគណបក្សនយោបាយ) ពីគណៈបក្សនយោបាយអាចជាឧបសគ្គសំរាប់គណៈបក្សក្នុងការចូលរួមក្នុងការបោះឆ្នោត ។

- **បទបញ្ញត្តិសំរាប់ការចុះឈ្មោះ យុទ្ធនាការឃោសនា និងការបោះឆ្នោត** ត្រូវផ្តល់ឱកាសឱ្យអ្នកបោះឆ្នោតអាចទៅបោះឆ្នោតបាន និងគណបក្សធ្វើការឃោសនាតាមដែលអាចធ្វើទៅបាន ។

ទាំងអស់នេះត្រូវធានាដោយច្បាប់បោះឆ្នោតតាមដែលអាចធ្វើទៅបាន និងមិនមែនធានាដោយបទបញ្ញត្តិរដ្ឋបាលរបស់ស្ថាប័នមួយដែលមិនបានជ្រើសរើសតាមលក្ខណៈប្រជាធិបតេយ្យនោះទេ ។ ដំណើរការទាំងមូលត្រូវត្រួតពិនិត្យដោយស្ថាប័នរដ្ឋបាលរៀបចំការបោះឆ្នោតឯករាជ្យមួយ ដែលត្រូវបានបង្កើតដោយលក្ខណៈជាចំហរ និងមានតម្លាភាពបំផុតដែលអាចធ្វើទៅបាន ។

[៤៥] មើលសំនួរសិក្សាទី១២

## ? **សំនួរសិក្សាទី ១២**

សូមអានជំពូកទី៧ ចំណុច ៧.១២.១៤ នៃបទបញ្ជារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ។

"គជប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្ទែកណាមួយ ឬសម្ភារៈអប់រំទាំងអស់ ដែលមិនគោរពទៅតាមចំណុច ៧.១២.៣ និង ៧.១៣.៨ ។ សាមីអង្គការត្រូវធ្វើការកែតម្រូវវាតាមសំណើររបស់ គជប ជាចាំបាច់ ។ ក្នុងករណីកំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីអង្គការត្រូវទទួលទោសតាម មាត្រា១៣១ នៃច្បាប់បោះឆ្នោត ។"

តើជំពូក៧, ១២, ១៤ នៃបទបញ្ជាបំពាននឹងច្បាប់ស្តីពីការបោះឆ្នោត (ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា) ដែរឬទេ? ចូរឱ្យមូលហេតុចំពោះចម្លើយរបស់អ្នក!

## ? **សំនួរសិក្សាទី ១៣**

ក. ចូរអានច្បាប់បោះឆ្នោត!
តើមាត្រាណាខ្លះនៃច្បាប់បោះឆ្នោតចែងអំពីទោសសំរាប់ទង្វើដែលជះឥទ្ធិពលអវិជ្ជមានលើដំណើរការបោះឆ្នោត? សូមរៀបរាប់មាត្រា និង ចំនួនមាត្រា!

ខ. តើមាត្រាណាខ្លះនៃក្រមព្រហ្មទណ្ឌចែងអំពីទោសសំរាប់ទង្វើដែលជះឥទ្ធិពលអវិជ្ជមានលើដំណើរការបោះឆ្នោត? សូមរៀបរាប់ និង ចំនួនមាត្រា!

គ. តើមាត្រាណាខ្លះនៃច្បាប់ស្តីពីការបោះឆ្នោត និង ក្រមព្រហ្មទណ្ឌហាមឃាត់ការទិញសន្លឹកឆ្នោត?



## **ករណីសិក្សាទី ២**

សម្តេចសង្ឃ **ទេព វង្ស** បានចេញ "ប្រកាស" មួយដែលហាមឃាត់ដល់លោកសង្ឃទាំងអស់មិនឱ្យទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៣នេះទេ ។

តើសម្តេចសង្ឃធ្វើបែបនេះស្របច្បាប់ដែរឬទេ?
ប្រើបញ្ជីផ្ទៀងផ្ទាត់នៅដែលបង្ហាញនៅទំព័រទី៣៣ រួចហើយឆ្លើយនូវសំនួរទាំងអស់នោះម្តងមួយៗ!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សង្ឃប្រកាស

អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស លើកទី ១១ បានប្រារព្ធពិធីបើកនៅសាលសន្និសីទចតុមុខ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** ហើយបានដំណើរការអស់ថេរវេលា៣ថ្ងៃ ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០២ នៅក្រសួងធម្មការ និង សាសនា ក្រោមព្រះរាជាធិបតីភាពសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ដោយ មានមន្ត្រីសង្ឃចំនួន ១២៦ អង្គ ចូលរួមជាសមាជិក និងមន្ត្រីធម្មការ និង សាសនា ចំនួន ៨០រូប ជាអ្នកសង្កេតការណ៍ ។ ដោយយោងតាមព្រះរាជបន្ទូលរបស់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃនេះ បានចេញសង្ឃប្រកាស ដែលមានខ្លឹមសារដូចខាងក្រោម :

**១. __ពង្រឹងការប្រតិបត្តិធម៌វិន័យ__ :**

-មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ធ្វើជាគម្រូក្នុងការគោរព បដិបត្តិត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និង អភិសមាចារ ។

-យកព្រះទ័យទុកដាក់ បង្រៀនណែនាំភិក្ខុគ្រប់រូបឱ្យចេះវិធីធ្វើសង្ឃកម្មនានា ចេះសំដែងភិក្ខុបាតិមោក្ខ និង ចូលរួមធ្វើឧបោសថកម្ម បានទៀងទាត់តាមកាលកំណត់ក្នុងព្រះវិន័យ ។

-អប់រំណែនាំ ភិក្ខុសាមណេរ ដែលជ្រុលប្រព្រឹត្តខុសឆ្គង ចេះស្ទុយភ្ញាក់រលឹក កែលំអ ខ្លួនឯងដើរត្រូវតាមគន្លងពុទ្ធវិន័យវិញ ។

-ខិតខំអប់រំ ពុទ្ធបរិស័ទ ឱ្យចេះតំកល់ខ្លួនប្រកបដោយសទ្ធានិងបញ្ញា ប្រតិបត្តិត្រឹមត្រូវតាមពុទ្ធឱវាទ លះបង់ជំនឿផ្តេសផ្តាស ប្រាសចាកគន្លងព្រះពុទ្ធសាសនាដោយគ្មានហេតុផល ហើយជ្រះថ្លាស្មោះស្ម័គ្រចូល រួមទ្រទ្រង់ ជាតិ សាសនា ព្រះមហាក្សត្រ ។

**២. __ពង្រឹងគុណភាពដឹកនាំ__ :**

-បន្តពង្រឹងរចនាសម្ព័ន្ធមន្ត្រីសង្ឃ និងជំរុញការ តែងតាំងមន្ត្រីសង្ឃពេញសិទ្ធិឱ្យបានឆាប់រហ័ស ។

-បំប៉នអំពីតួនាទី ភារកិច្ច បែបបទរដ្ឋបាល ដល់មន្ត្រីសង្ឃ គណៈកម្មការ អាចារ្យវត្ត សំដៅគ្រប់គ្រងវត្តអារាម ធានាបានប្រសិទ្ធភាពខ្ពស់ ។

-ត្រូវចារបញ្ជាក់ថា បានសិក្ខា លើសង្ឃដិកា បួសនាយា នៃបព្វជិតដែលបានលាចាកសិក្ខាបទទៅជាគ្រហស្ថវិញ ។

-២-

៣.ពង្រឹងគុណភាពពុទ្ធិកសិក្សា :

-ជំរុញការពង្រឹង ពង្រីក (កម្រង) ប្រព័ន្ធ សាលាពុទ្ធិកបឋមសិក្សា , សាលាធម្មវិន័យ និងមជ្ឈមណ្ឌលវិបស្សនា គ្រប់ស្រុក-ខ័ណ្ឌ ទូទាំងប្រទេស ។

-បន្តការពង្រឹងពង្រីកសហគមន៍សង្ឃ ទ្រទ្រង់ពុទ្ធិកសិក្សា និងពុទ្ធិកសង្គហកុមារ នៅតាមវត្តអារាម ។

-ខិតខំអប់រំកុមារនិងយុវជនកំព្រា ក្រីក្រ ដែលស្នាក់អាស្រ័យនៅក្នុងវត្តអារាម ឱ្យប្រកាន់ខ្ជាប់នូវ សណ្ដាប់ធ្នាប់ បញ្ញាសីល និងចរិយាធម៌ ។

-មន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ មានព្រះគ្រូចៅអធិការជាដើម ទូទាំងប្រទេសត្រូវធ្វើការបណ្តុះបណ្តាលបព្វជិត និងគ្រហស្ថ ដើម្បីឱ្យទៅជាគ្រូបង្គោល ពុទ្ធិកសង្គហកុមារ ។

៤.ព្រះសង្ឃនិងការបោះឆ្នោតគាំទ្រគណបក្សនយោបាយ :

-ព្រះសង្ឃទាំងបច្ចុប្បន្ន ទាំងអនាគត ត្រូវប្រកាន់គោលជំហរអព្យាក្រឹត មិនចូលរួមបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយឡើយ ប៉ុន្តែត្រូវរក្សាសិទ្ធិបោះឆ្នោតនេះនៅពេលអនាគតដែលមានការចាំបាច់បំផុត ។

-ពិនិត្យរារាំងនូវគ្រប់រូបភាពអសកម្ម ដែលឆ្លៀតឱកាសយកព្រះសង្ឃ ឬ ព្រះពុទ្ធសាសនាទៅ ប្រើប្រាស់ខុសចាកគន្លងធម៌វិន័យ ។

-មិនអនុញ្ញាតឱ្យមានអន្តរសាសនាណាមួយ ដែលប្រព្រឹត្តប្រាសចាកប្រពៃណី ទំនៀមទំលាប់ខ្មែរ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

៥.ការទារអធិករណ៍ :

-មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ ត្រូវមានកម្មវិធីអប់រំភិក្ខុ សាមណេរ គណៈកម្មការ អាចារ្យ វត្តពង្រឹងសាមគ្គីភាពផ្ទៃក្នុង រារាំងគ្រប់រូបភាពអធិករណ៍ កុំឱ្យកើតមានក្នុងវត្តអារាម ។

-ប្រកាន់ជំហរម្ចាស់ការដោះស្រាយរាល់អធិករណ៍ ដែលជាសមត្ថកិច្ចខ្លួន ដោយប្រកាន់គោលការណ៍ សម្រុះសម្រួលផ្សះផ្សារជាកត្តាគន្លឹះ ។

៦.ការទារអភិបាលកិច្ចសង្ឃ :

-អភិបាលកិច្ចសង្ឃ ត្រូវចុះស្រាវជ្រាវរាល់បាតុភាព អធិករណ៍ ដែលកើតមានឡើង ដោយសហការជាមួយមន្ត្រីសង្ឃ មន្ត្រីធម្មការមូលដ្ឋាន ។

-អភិបាលកិច្ចសង្ឃខេត្ត-ក្រុង គ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយ មន្ត្រីធម្មការ និងសាសនារាល់ការដោះស្រាយអធិករណ៍ ។

៧_<u>អបអរសាទរសន្និសីទកំពូលពុទ្ធសាសនាលើកទី ៣</u> :

**ចូលរួមអបអរសាទរដោយធ្វើសកម្មភាពជាក់ស្តែង :**

- ព្រះមេគណ ឬ អនុគណ ត្រូវណែនាំព្រះគ្រូចៅអធិការ ព្រះសង្ឃ ឱ្យរៀបចំវត្តអារាមឱ្យមានអនាម័យ និងដាំកូនឈើឱ្យមានសម្រស់បរិស្ថានធម្មជាតិ គួរជាទីជ្រះថ្លា គោរពបូជារបស់ពុទ្ធបរិស័ទ និងភ្ញៀវទេសចរទូទៅ ។

- ចំពោះវត្តអារាមដែលមានសម្បត្តិវប្បធម៌ ប្រាង្គ ប្រាសាទ បេតិកភណ្ឌជាតិ រមណីយដ្ឋាននិងតំបន់ទេសចរ ត្រូវខិតខំថែទាំយ៉ាងម៉ឺងម៉ាត់ ធានាបានទាំងរបៀបរៀប រយទាំងសុវត្ថិភាព ។

- មន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់ ព្រមទាំងព្រះធម្មកថិក ត្រូវទេសនា ជួយអប់រំ បំបាត់អបាយមុខទាំងបីប្រការ ( ល្បែង , ស្រា , ស្រី) ដើម្បីឱ្យប្រជាពលរដ្ឋ មានការភ្ញាក់រលឹកកាត់បន្ថយ ដោយស្ម័យប្រវត្តិ ។

សង្ឃប្រកាសនេះ ជាច្បាប់សម្រាប់អនុវត្តនៅគ្រប់វត្តអារាម ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

រាល់លិខិតបទដ្ឋានណា ដែលផ្ទុយពីខ្លឹមសារ នៃសង្ឃប្រកាសនេះ ទុកជានិរាករណ៍ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០២

**សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ**
**ព្រះសុគន្ធាធិបតី**

សម្តេចព្រះសង្ឃរាជ បួរ គ្រី

**សម្តេចព្រះសង្ឃរាជគណៈមហានិកាយ**
**ព្រះមហាសុមេធាធិបតី**

បានឃើញ និងឯកភាព
**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

ជា_សាវឿន

## បញ្ជីផ្ទៀងផ្ទាត់ ដើម្បីដោះស្រាយករណីសិទ្ធិមនុស្ស!

**១. តើបុគ្គល និងស្ថាប័នណាខ្លះដែលពាក់ព័ន្ធនៅក្នុងវិវាទ?**

តើនរណាកំពុងធ្វើសកម្មភាពនៅក្នុងករណីនេះ? តើនរណាដែលពាក់ពន្ធ័? តើស្ថាបន័ណាខ្លះដែលបានធ្វើសកម្មភាព ឬចាំបាច់ត្រូវធ្វើសកម្មភាព?

*សូមគូរក្រាហ្វិកមួយ:*

*សូមប្រើប្រាស់* ● *សម្រាប់មនុស្ស* *សូមប្រើប្រាស់* ■ *សម្រាប់ស្ថាប័ន*

**២. តើអ្វីទៅជាផលប្រយោជន៍របស់មនុស្ស ឬស្ថាបន័ដែលពាក់ពន្ធ័នោះ?**

*សូមគូរក្រាហ្វិកមួយ:*

*សូមប្រើប្រាស់សញ្ញា* ← *ព្រួញនេះដើម្បីបង្ហាញនូវផលប្រយោជន៍ផ្សេងៗគ្នានៃ*
→ *បុគ្គល និងស្ថាប័នដែលពាក់ព័ន្ធ ។*

**៣. សិទ្ធិ និងភារកិច្ច**

**ក. តើសិទ្ធិមនុស្ស និងភារកិច្ចណាខ្លះដែលត្រូវប៉ះពាល់?**

*សូមមើលរដ្ឋធម្មនុញ្ញ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាអន្តរជាតិដទៃទៀត! តើអ្នករកឃើញសិទ្ធិអ្វីខ្លះនៅក្នុងនោះ? តើមាត្រាណាមួយអាចទាក់ទងទៅនឹងបុគ្គលដែលពាក់ពន្ធ័? ចូររៀបរាប់មាត្រាសិទ្ធិមនុស្សឱ្យបានច្បាស់លាស់ (ឧទាហរណ៏: មាត្រា៤១ កថាខណ្ឌ័១ ប្រយោគ១ នៃរដ្ឋធម្មនុញ្ញកម្ពុជា = មាត្រា៤១ I ១ CC)!*

ជានិច្ចកាលមិនត្រឹមតែព្យាយាមរកមើលសិទ្ធិទូទៅប៉ុណ្ណោះទេ ប៉ុន្តែត្រូវរកមើលសិទ្ធិពិសេសៗបំផុតផងដែរ!

ឧទាហរណ៏: សិទ្ធិក្នុងការចូលរួមក្នុងនយោបាយ (មាត្រា ៣៥ I CC ) គឺគ្រាន់តែជាសិទ្ធិមួយដែលផ្តល់នូវឱកាសទូទៅមួយដើម្បីចូលរួមក្នុងនយោបាយកិច្ចការសង្គម និងវប្បធម៌ ។ សិទ្ធិនេះគ្របដណ្តប់យ៉ាងទូលំទូលាយលើប្រភេទផ្សេងៗនៃ

ការចូលរួម ។ វាមិនបានបញ្ជាក់ឱ្យច្បាស់នូវសិទ្ធិក្នុងការចូលរួមក្នុងនយោបាយតាមរយៈការបោះឆ្នោត ។ សម្រាប់រូបភាពពិសេសនៃការចូលរួមក្នុងនយោបាយមួយនេះ មានសិទ្ធិពិសេសមួយៈ សិទ្ធិក្នុងកាបោះឆ្នោត (មាត្រា ៣៤ I CC )។ ដូច្នេះមិនត្រូវដកស្រង់សិទ្ធិទូទៅឡើយ (មាត្រា ៣៥ I CC ) គឺត្រូវដកស្រង់ត្រឹមតែសិទ្ធិពិសេស១តែប៉ុណ្ណោះ (មាត្រា ៣៤ I CC )។

**៦. តើភារកិច្ចស្របច្បាប់របស់ស្ថាប័នដែលពាក់ពន្ធ័មានអ្វីខ្លះ?**

*មើលនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់នានា!*

រដ្ឋាភិបាល ឬអាជ្ញាធរដទៃទៀតរបស់រដ្ឋ មិនមែនជាមនុស្សឡើយ គឺវាជាស្ថាបន័ ។ ព្រោះហេតុដូច្នេះហើយ ក្នុងនាមជាស្ថាបន័ គេមិនអាចមានសិទ្ធិ *មនុស្ស* ឡើយ ។ ប៉ុន្តែ មានប្រការខ្លះនៅក្នុងរដ្ឋធម្មនុញ្ញ ឬនៅក្នុងច្បាប់ដែលផ្តល់អំណាចឱ្យស្ថាប័នទាំងនេះធ្វើសកម្មភាព និងផ្តល់ភារកិច្ចដល់គេឱ្យធ្វើសកម្មភាព។ ដូច្នេះស្ថាប័ន ទាំងនេះក៏មានសិទ្ធិ និងភារកិច្ចផងដែរ។

**៤. តើពាក្យផ្សេងៗនៅក្នុងមាត្រាសិទ្ធិមនុស្ស មានអត្ថន័យដូចម្តេច?**

*សូមមើលពាក្យ នីមួយៗនៃមាត្រាច្បាប់ដោយឡែកៗពីគ្នា ។ ឧទាហរណ៍ : អ្វីទៅដែលមានន័យថា ការបោះឆ្នោត "ដោយសេរី" ក្នុងមាត្រា៧៦ II CC? ឬ ពាក្យថា "ការបញ្ចេញមតិ" ក្នុងមាត្រា៤១ I ១ CC?*

*តើអ្នកអាចរកឃើញការផ្តល់យោបល់ ទស្សនៈ គំនិត ដែលអាចជួយអ្នកក្នុងការបកស្រាយអត្ថន័យរបស់ពាក្យនេះនៅកន្លែងណា?*

សៀវភៅអធិប្បាយ និងសាលក្រម ដែលយោងលើមាត្រានៃសិទ្ធិមនុស្សនៃរដ្ឋធម្មនុញ្ញកម្ពុជា កម្រនឹងរកមានណាស់នៅកម្ពុជា ។ ហេតុដូច្នេះហើយ ជាដំបូងអ្នកត្រូវតែរកមាត្រានៃអនុសញ្ញាអន្តរជាតិមួយដែលវែកញែក អំពីប្រធានបទដូចគ្នានោះ។ បន្ទាប់មកអ្នកត្រូវរកមើលការអធិប្បាយលើមាត្រាអន្តរជាតិនេះ ។

ឧទាហរណ៍:

- ប្រសិនបើអ្នកមិនដឹងថា ពាក្យការបោះឆ្នោត "ដោយសេរី " នៅក្នុងមាត្រា ៧៦ II CC មានន័យថាម៉េចទេ អ្នកអាចមើលមាត្រា២៥ ICCPR ដែលធានានូវការបោះឆ្នោត "ដោយសេរី" ដូចគ្នា ។ ការអធិប្បាយទៅលើមាត្រាអន្តរជាតិនេះក៏មានដែរ ។ ប្រសិនបើអ្នកពិនិត្យមើលការអធិប្បាយទូទៅរបស់គណៈកម្មាការ សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិទៅលើមាត្រា២៥ ICCPR វានឹងផ្តល់ឱ្យអ្នកនូវគំនិតមួយថាតើអ្វី ទៅជា "ការបោះឆ្នោតដោយសេរី" និងធ្វើទៅជាគោលបំណងនៃការការពារសេរីភាពនេះ ។ នៅលើគេហទំព័រ : www.unchr.ch ចុចពាក្យ "treaties (សន្ធិសញ្ញា)" រួចហើយចុចពាក្យ "general comment (ការអធិប្បាយ ជាទូទៅ)" ទៅលើមាត្រា២៥ ICCPR ។
- ប្រសិនបើអ្នកមិនដឹងថាតើពាក្យថា "ការរំលោភបំពានលើរាងកាយ" ឬពាក្យថា "ប្រព្រឹត្តកម្មផ្សេងៗទៀតដែលបន្ថែមទំងន់ទណ្ឌកម្ម" នៅក្នុងមាត្រា ៣៨ IV CC អាចមានន័យដូចម្តេចទេ អ្នកអាចមើលអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការធ្វើទារុណកម្ម ដែលផ្តល់ឱ្យអ្នកនូវនិយមនយ័នៃពាក្យ "ការធ្វើទារុណ្ណកម្ម" នៅក្នុងមាត្រា១ ។ ឬក៏អ្នកអាចមើល សេចក្តីថ្លែងការណ៍ ឬសេចក្តីសម្រេចអំពីសិទ្ធិរបស់អ្នកទោស និងអ្នកជាប់ឃុំ ។(សូមមើលដូចជា គេហទំព័ររបស់ សាកលវិទ្យាលយ័សិទ្ធិមនុស្សមីនីសូតាៈ www1.umn.edu/humanrts រួចហើយចុចៈ "Treaties and other international

Instruments" នៅក្នុងមាតិកា "Human Rights Documents and Materials" រួចហើយចុច "Treaties and other instruments organized by subject matter" រួចហើយចុច "Rights of Prisoners and Detainees" ឬក៏ចុច "Protection from Torture, Ill-Treatment and Disappearance" ។ លើគេហទំព័រនេះ អ្នកនឹងរកឃើញ សេចក្ដីថ្លែងការណ៍ និងសេចក្ដីសម្រេចគ្រប់ប្រភេទ ទាំងអស់ដែលផ្ដល់សេចក្ដីពិស្ដារ និងគំនិតបន្ថែមអំពីថាតើគេគួរតែប្រព្រឹត្ត និងការពារដូចម្ដេចទៅលើអ្នកទោស ។) **គោលការណ៍ និងសេចក្ដីថ្លែងការណ៍ទាំងនេះមិនមានជាប់ជំពាក់អ្វីឡើយ** ប៉ុន្តែវាផ្ដល់នូវមធ្យោបាយដ៏មានប្រយោជន៍មួយសម្រាប់ធ្វើការបកស្រាយហើយវាផ្ដល់ឱ្យអ្នកនូវគំនិតមួយថា តើអ្វីទៅដែលគេចាត់ទុកថា "ការរំលោភបំពាន" ទៅលើអ្នកទោស ។

- ប្រសិនបើអ្នកចង់ដឹងបន្ថែម អំពីពាក្យ "សេរីភាពក្នុងការបញ្ចេញមតិ" នៅក្នុងមាត្រា ៤១ I ១ CC អ្នកត្រូវ មើលមាត្រា ១៩ II ICCPR ដែលផ្ដល់ការការពារដល់សេរីភាពនេះដែរ ហើយវាផ្ដល់នូវសេចក្ដីពិស្ដារអំពី វិសាលភាពនៃសេរីភាពនេះ ។ ប្រសិនបើអ្នកត្រូវការប្រភពពត៌មានបន្ថែមដែលមានប្រយោជន៍អំពីសិទ្ធិមនុស្សណាមួយ អ្នកអាចមើលគេហទំព័រ *បណ្ដាញសិទ្ធិមនុស្សអន្តរជាតិ* (Hunan Rights Netnork International) របស់សាកលវិទ្យាល័យប្រាសសែលស៍ (សូមបើកមើល www.hrni.org រួចចុចៈ "Rights and Freedom" រួចហើយចុច "Qualified rights" បន្ទាប់មកចុច "freedom of expression") ។ នៅទីនោះ អ្នកអាចរកឃើញយុត្តិសាស្ត្រ (សេចក្ដីសម្រេចនៃស្ថាប័នអន្តរជាតិ ដូចជា តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការសិទ្ធិមនុស្សអន្តរអាមេរិក ឬគណៈកម្មាការសិទ្ធិមនុស្ស ឧទាហរណ៍ៈ នៅលើករណីនៃសេរីភាពក្នុងការបញ្ចេញមតិ) លិខិតុបករណ៍ជាក់លាក់នានា (សេចក្ដីថ្លែងការណ៍ និងសេចក្ដីសម្រេចអន្តរជាតិ, ដូចជា អំពីសេរីភាពក្នុងការនិយាយស្ដីដូចជាសេចក្ដី ថ្លែងការណ៍ ចូហាណេស្បឺក) មាត្រាផ្សេងៗ (អត្ថបទនិពន្ធនានាអំពីប្រធានបទនេះ) អាសយ័ដ្ឋានគេហទំព័រពិសេសៗ (ឧទាហរណ៍គេហទំព័ររបស់ វិទ្យាស្ថានសារពត៌មានអន្តរជាតិ) ជាដើម ។

**៥. តើមាត្រាសិទ្ធិមនុស្សអាចអនុវត្តចំពោះករណីជាក់លាក់ដែរឬទេ?**

*ចូរពិនិត្យមើលមាត្រាបន្តិចម្ដងៗ និងមួយពាក្យម្ដងៗ!*

**៦. តើមានការដាក់កំហិតអ្វីខ្លះទៅលើសិទ្ធិមនុស្សនេះ?**

*សូមអានម្ដងទៀតនូវមាត្រាសិទ្ធិមនុស្សនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និង ICCPR ដោយប្រុងប្រយត្ន័ : តើមានផ្នែកណាមួយនៃមាត្រានេះ ដែលនិយាយយោងទៅលើការដាក់កំហិតណាមួយដែលអាចកើតមានឬទេ? តើអ្វីទៅដែលជា លក្ខខណ្ឌ័ដ៏ជាក់លាក់សម្រាប់ការដាក់កំហិត ដែលរៀបរាប់នៅក្នុងមាត្រានេះ?*

*កំណត់ចំណាំ:*

*ជានិច្ចកាល ត្រូវពិនិត្យមើលជាមុនសិននូវការដាក់កំហិតពិសេសៗនៅក្នុងអត្ថបទច្បាប់នៃមាត្រាសិទ្ធិមនុស្សពិសេសៗ ។ លើកលែងតែអ្នកមិនអាចរកឃើញនូវការដាក់កំហិតពិសេសណាមួយនោះទេ អ្នកអាចពិនិត្យមើល* ***ការដាក់កំហិតជា ទូទៅនៅក្នុងមាត្រា៣១ II ២ CC*** *ដែលចែងថាការអនុវត្តសិទ្ធិមួយមិនត្រូវឱ្យប៉ះពាល់ដោយអវិជ្ជមានទៅលើសិទ្ធិរបស់អ្នកដ៏ទៃនោះទេ ។ ក្នុងករណីនេះ ការដាក់កំហិតទៅលើការអនុវត្តន៍សិទ្ធិអាចត្រូវកំណត់ឡើងដោយច្បាប់សាមញ្ញមួយ (មាត្រា៣១ II ៣ CC) ដែលត្រូវតែមានគោលបំណងការពារសិទ្ធិរបស់មនុស្សម្នាក់ទៀត និងដែលគ្រាន់តែអនុញ្ញាតឱ្យអាជ្ញាធរអាចកំណត់នូការដាក់កំហិតដែលសមស្រប ដែលចាំបាច់*

*ដើម្បីសម្រេចនូវគោលបំណងនេះ តែប៉ុណ្ណោះ ( "គោលការណ៍ នៃភាពសមាមាត្រ" ) ។*

ឧទាហរណ៍ :
សេរីភាពនៃការបញ្ចេញមតិៈ មាត្រា៤១ I ២ CC មានរៀបរាប់អំពីសិទ្ធិនានារបស់មនុស្សដទៃ ទំនៀមប្រពៃណីរបស់សង្គម នីតិ និងសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ ។ វាពុំបានពិនិត្យមើលទៅលើការដាក់កំហិតលើការបញ្ចេញមតិដោយសេរី ក្នុងគោលបំណងដើម្បីការពារ "ស្ថេរភាពនយោបាយ" នោះឡើយ (ដូចជានៅក្នុង មាត្រា១២ I នៃច្បាប់សារពត៌មាន) ។ មាត្រា១៩ II ICCPR អនុញ្ញាតឱ្យមានការដាក់កំហិតបន្ថែមទៅលើការបញ្ចេញមតិ ដើម្បីការពារ "សុខមាលភាពសាធារណៈ" និង "សីលធម៌" ។

## ៧. តើមានច្បាប់ពិសេសណាខ្លះដែលដាក់កំហិតទៅលើសិទ្ធិមនុស្សដែរឬទេ? សូមអនុវត្តច្បាប់នេះចំពោះករណីមួយ!

*ទីមួយ ចូររកមើលច្បាប់កម្ពុជាទាំងឡាយដែលពាក់ព័ន្ធនឹងប្រធានបទ!*

ច្បាប់សាមញ្ញ បញ្ញត្តិនូវសេចក្តីពិស្តារនៃការដាក់កំហិតដែលមាននៅក្នុងរដ្ឋធម្មនុញ្ញៈ អ្នកបង្កើតច្បាប់នៅរដ្ឋសភា ពោលគឺ មិនមែន(!) រដ្ឋមន្ត្រី ឬអភិបាលខេត្ត ឬក៏សមាជិកណាម្នាក់នៃអំណាចនីតិប្រតិបត្តិ ត្រូវតែស្វែងរកតុល្យភាព រវាងសិទ្ធិមនុស្សផ្សេងៗគ្នានៃមនុស្សផ្សេងៗគ្នា ។ អ្នកបង្កើតច្បាប់ត្រូវតែកំណត់ថាតើការដាក់កំហិតណាមួយដែលត្រូវប្រើទៅលើការអនុវត្តន៍សិទ្ធិមនុស្សមួយ ដើម្បីការពារសិទ្ធិមនុស្សមួយទៀត ។ អ្នកបង្កើតច្បាប់ត្រូវប្រុងប្រយ័ត្នថា ច្បាប់គ្រាន់តែដាក់ចេញនូវការដាក់កំហិតនានាដែលចាំបាច់ (ឬសមាមាត្រ) ក្នុងការសម្រេចនូវគោលបំណងរបស់គេ ។ អ្នកបង្កើតច្បាប់ត្រូវគោរពតាមមាត្រានានានៃរដ្ឋធម្មនុញ្ញ ។ ពួកគេគ្រាន់តែអាចដាក់កំហិតណាមួយដែលអនុញ្ញាតដោយរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ (គឺដោយមាត្រាដែលចែងពីសិទ្ធិមនុស្សពិសេស ឬដោយបញ្ញត្តិជាទូទៅនៅក្នុងមាត្រា៣១ II ២) ។

ឧទាហរណ៍ :

- នៅក្នុងករណីសិទ្ធិមនុស្សមួយដែលទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិ អ្នកនឹងត្រូវរកមើលបទបញ្ញត្តិនានា នៅក្នុងច្បាប់សារពត៌មាន ។ មាត្រា១០ ដល់មាត្រា១៦ នៃច្បាប់សារពត៌មានរៀបរាប់នូវការដាក់កំហិតផ្សេងៗ ដែលអាចត្រូវបានកំណត់ក្រោមលក្ខណខណ្ឌផ្សេងៗ។
- ទាក់ទងនឹងសេរីភាពក្នុងការជួបប្រជុំ អ្នកនឹងត្រូវពិនិត្យមើលច្បាប់អំពីការធ្វើបាតុកម្ម ។
- កុំភ្លេចពិនិត្យមើលច្បាប់ព្រហ្មទណ្ឌ(!) ច្បាប់នេះផ្តល់នូវការដាក់កំហិតច្រើនចំពោះប្រធានបទផ្សេងៗផងដែរ ។ ឧទាហរណ៍ ការដាក់ទណ្ឌកម្មទៅលើសេរីភាពនៃការនិយាយស្តី ក្នុងករណីនៃការបរិហារកេរ្តិ៍ ឬការដាក់ទណ្ឌកម្ម ទៅលើការរំលោភសិទ្ធិរបស់អ្នកបោះឆ្នោត ។

*ទីពីរ ស្រាវជ្រាវនៅក្នុងច្បាប់ទាំងនោះឱ្យបានស៊ីជំរៅ លើវិធានការណ៍ ដាក់កំហិត និងអនុវត្តច្បាប់ទាំងនោះទៅលើករណីមួយជំហានម្តងៗ និងមួយពាក្យម្តងៗ!*

ឧទាហរណ៏:

មាត្រា៦៤ នៃច្បាប់ព្រហ្មទណ្ឌចែងថា :

" *ជនណាក៏ដោយ* តាមរយៈ *ការគំរាមកំហែង ការឈ្លានពានលើរូបរាងកាយ ការបង្ខិតបង្ខំប្រភេទណាក៏ដោយ ជ្រៀតជ្រែក* ដល់ *ការអនុវត្តន៏ដោយសេរីនៃ សិទ្ធិបោះឆ្នោតរបស់អ្នកបោះឆ្នោត ឬសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់បេក្ខជន* ឬដល់ *ភាពត្រឹមត្រូវនៃដំណើរការបោះឆ្នោត* ត្រូវជាប់ពិរុទ្ធពីបទបន្លំក្នុងការបោះឆ្នោត ហើយនឹងត្រូវផ្តន្ទាទោសដាក់គុកពី ១ ទៅ ៣ឆ្នាំ ។"

*សូមវែកញែកពាក្យដូចខាងក្រោម ÷*

**នរណា...**

**តាមរយៈ ...**
- ការគំរាមកំហែង ឬ
- អាកប្បកិរិយាខុសច្បាប់ ឬ
- ការបង្ខិតបង្ខំក្នុងរូបភាពណាមួយ

**ជ្រៀតជ្រែកដល់ ...**
- ការអនុវត្តន៏ដោយសេរីនូវសិទ្ធិបោះឆ្នោតនៃ
  - អ្នកបោះឆ្នោត
  - បេក្ខជន

ឬ

- ការប្រព្រឹត្តទៅដោយត្រឹមត្រូវនៃការបោះឆ្នោត

**... គឺជាពិរុទ្ធនៃការបន្លំក្នុងការបោះឆ្នោត ។**

*បន្ទាប់មកត្រូវឆ្លើយនឹងសំណួរនេះ: តើសម្តេចសង្ឃរាជបានប្រើប្រាស់ការគំរាមកំហែង ឬអាកប្បកិរិយាខុសច្បាប់ ឬការបង្ខិតបង្ខំ ដើម្បីជ្រៀតជ្រែកទៅក្នុងការអនុវត្តសិទ្ធិរបស់អ្នកបោះឆ្នោតដែរឬទេ?*

**៨. តើការដាក់កំហិតដែលបានកំណត់នោះ មានលក្ខណៈសមាមាត្រឬទេ ឬក៏ខ្លាំងពេក?**
**("គោលការណ៏នៃភាពសមាមាត្រ")**

*ទីមួយ ចូរពិនិត្យមើលតើច្បាប់បញ្ញត្តិនូវវិធានការអ្វីខ្លះក្នុងការដាក់កំហិត?*

ឧទាហរណ៍: ច្បាប់សារពត៌មាន រាប់បញ្ចូលនូវ:

- តុលាការស៊ីវិល : បទបញ្ជាឱ្យកែតម្រូវ បទបញ្ជាឱ្យសងជម្ងឺចិត្តជាទឹកប្រាក់ ឬទាំងពីរ (មាត្រា១០ III)
- ការពិន័យដោយក្រសួងពត៌មាន (មាត្រា១១ II, ១២ II)
- ទោសព្រហ្មទណ្ឌ ដោយយោងតាមក្រមព្រហ្មទណ្ឌ (មាត្រា ១២ II)

*ទីពីរ សូមចាត់ថ្នាក់ លើវិធានការណ៍ផ្សេងៗទាំងនោះទៅតាមកំរិតរបស់វា: តើអ្វីទៅជាវិធានការធូរស្រាលជាងគេ? តើអ្វីទៅជាវិធានការដែលខ្លាំងជាងគេ?*

*ទីបី តើអ្វីទៅជាវិធានការដែលនាំមកនូវលទ្ធផលប្រសើរបំផុត ដោយមាន ការខូចខាតតិចបំផុត ចំពោះសិទ្ធិមនុស្ស?*

ឧទាហរណ៍:

វាមិនចាំបាច់ដាក់ពិន័យទៅលើកាសែតពីបទបរិហារកេរ្តិ៍នោះឡើយ នៅពេលដែលគេអាចចេញជាបទបញ្ជាឱ្យកែតម្រូវ វាគ្រប់គ្រាន់ហើយដើម្បីដោះស្រាយបញ្ហានោះ ។